អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ១៦ ចេញផ្សាយ ខែមេសា ឆ្នាំ២០២៣

## ប្រសិទ្ធផលប្រតិបត្តិការ

ការគ្រប់គ្រងប្រតិបត្តិការ សំដៅទៅលើការគ្រប់គ្រងការអនុវត្តរបស់ស្ថាប័នដើម្បីទទួលបាននូវកម្រិតប្រសិទ្ធភាព និងប្រសិទ្ធផលអតិបរមាទាក់ទងនឹងការប្រើប្រាស់ធនធាន។ ការគ្រប់គ្រងប្រតិបត្តិការ គឺពាក់ព័ន្ធនឹងសកម្មភាពការសម្រេចចិត្ត និងទំនួលខុសត្រូវរបស់អ្នកគ្រប់គ្រងស្ថាប័ន ដើម្បីធានាថាផលិតផល និងសេវាដែលស្ថាប័នបានផ្តល់ជូនអតិថិជនមានគុណភាព និងមានអត្ថប្រយោជន៍ខ្ពស់។ តាមរយៈនេះ គ្រប់ស្ថាប័នទាំងអស់ទាមទារឱ្យមានការតាមដានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំទៅលើប្រតិបត្តិការរបស់ខ្លួន ថាតើប្រតិបត្តិការទាំងនោះបានដំណើរការប្រកបដោយប្រសិទ្ធផលដែរឬទេ?




### និយមន័យ

ប្រសិទ្ធផល សំដៅទៅដល់ការសម្រេចបានដល់គោលដៅអតិបរមាជាមួយនឹងធនធានដែលបានកំណត់ ឬក៏សម្រេចដល់គោលដៅដែលបានកំណត់ដោយប្រើប្រាស់ធនធានតិចជាងធនធានដែលបានកំណត់។ក្នុងន័យនេះ ប្រសិទ្ធផល ឬស័ក្តិសិទ្ធភាព សំដៅដល់÷

**១.** ការសម្រេចបានផលខ្ពស់ជាងការរំពឹងទុក ជាមួយនឹងធនធានដែលបានកំណត់។ **ឧទាហរណ៍÷** ការរៀបចំចុះត្រួត-ពិនិត្យក្រុមហ៊ុនដល់ទីកន្លែងរបស់និយ័តករ ដោយបានគ្រោងក្នុងផែនការចំនួន ២០ ក្រុមហ៊ុនក្នុងឆ្នាំ២០២២ ដោយកំណត់មន្ត្រីចុះត្រួតពិនិត្យមានចំនួន ១០ នាក់។ ជាលទ្ធផល និយ័តករបានចុះត្រួតពិនិត្យចំនួន ៣០ ក្រុមហ៊ុន ក្នុងមួយឆ្នាំ ដោយកំណត់មន្ត្រីចុះត្រួតពិនិត្យមានចំនួន ១០ នាក់ដដែល។




**២.** ការសម្រេចបានគោលដៅដែលបានកំណត់ដូចគ្នា ដោយប្រើប្រាស់ធនធានតិចជាងមុន (ជាបរិមាណ និងគុណភាពរបស់លទ្ធផល)។ **ឧទាហរណ៍÷**ជាធម្មតាគេមានតម្រូវការកសិករចំនួន ១០ នាក់ ដើម្បីធ្វើស្រែទទួលបានទិន្នផល ១០ តោនក្នុងមួយឆ្នាំ ប៉ុន្តែឥឡូវនេះគេត្រូវការកសិករត្រឹមតែចំនួន ៧ នាក់ប៉ុណ្ណោះដើម្បីធ្វើស្រែលើទំហំផ្ទៃដីដដែល ដោយទទួលបានទិន្នផល ១០ តោនក្នុងមួយឆ្នាំដូចគ្នា។

ជារួម ប្រសិនបើស្ថាប័នមួយមានប្រតិបត្តិការការងារប្រកបដោយប្រសិទ្ធផល នោះនឹងនាំឱ្យសម្រេចបាននូវផលវិជ្ជមានជាច្រើន ដែលជួយឱ្យកាត់បន្ថយការចំណាយ និងទទួលបានលទ្ធផលជាអតិបរមាពីធនធានដែលបានកំណត់។

**អត្ថបទ÷** កញ្ញា **សំ ឆេងហួយ**

**ឯកសារយោង÷**

*១- ឧត្តមានុវត្តន៍នៃការគ្រប់គ្រងប្រតិបត្តិការរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ* ***អ.ស.ហ.***

*២- គោលការណ៍ណែនាំសវនកម្មសមិទ្ធកម្មរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ* ***អ.ស.ហ.*** *។*

អត្ថបទអប់រំខ្លីៗស្តីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.

ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

ស្កេនទាញយកអត្ថបទស្តីពីសវនកម្មផ្សេងទៀត

www.iauoffsa.gov.kh